នស/រកត/០៣០១/០៤៩ **ព្រះរាជក្រឹត្យ**

# ស្តីពី
# សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី
# នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ
# របស់ក្រសួងមហាផ្ទៃ

## យើង
## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វង្សុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ នៃក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនា ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០១។

# ត្រាស់បង្គាប់

## ជំពូកទី ១
## បទប្បញ្ញត្តទូទៅ

**មាត្រា ១.–**

ត្រូវបានបង្កើត សញ្ញាស័ក្តិ ឯកសណ្ឋានសម្រាប់សំគាល់មន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ ដែលស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ។

**មាត្រា ២.–**

សញ្ញាស័ក្តិ និងឯកសណ្ឋាននេះ សម្រាប់ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធី ផ្លូវការផ្សេងៗ។

## ជំពូកទី ២
## សញ្ញាស័ក្តិ

**មាត្រា ៣.–**

សញ្ញាស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការរបស់ក្រសួងមហាផ្ទៃត្រូវបានកំណត់ដូចតទៅ:

**ក- ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់**

**១- <u>អំពីមួក</u>**

មួកកាសស្កេតពណ៌ស និងមានក្បាំងខាងមុខពណ៌ខៀវចាស់។ នៅផ្នែកខាងលើមុខមួក មានប៉ាក់ឱនរូបព្រះរាជសង្ហារពណ៌មាស។ ជាយក្បាំងខាងលើ មានផ្ទៃពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់ផ្កាឈូកបីទងពណ៌មាសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសមាសនៅសងខាង។ ចំកណ្តាលក្បាំងមានខ្សែវ័ណ្ឌក្រឡាក្អែបពណ៌នៅពីលើហើយនៅចុងទាំងសងខាងនៃខ្សែក្រឡាក្អែមនេះ មានលំអដោយឡេវរូបព្រះរាជសង្ហារពណ៌មាសមួយ។ ជាយក្បាំងខាងមុខមានរចនាតុបតែងដោយក្បាច់ផ្កាឈូកបីស្រទាប់ពណ៌មាសនៅចំកណ្តាល បន្ទាប់មកមានក្បាច់កួរស្រូវ និងក្បាច់សន្លឹកភ្ញីទេសនៅអមសងខាងផង។ ជាយក្បាំងខាងមុខមួកនេះ មានក្បាច់រចនាពេញចំពោះឋានន្តរស័ក្តិឧត្តមមន្ត្រី ពីរភាគបី ចំពោះឋានន្តរស័ក្តិវរៈមន្ត្រី និងមួយកន្លះភាគបីចំពោះឋានន្តរស័ក្តិអនុមន្ត្រី។ នៅចុងជាយក្បាំងខាងក្រោមបង្អស់មានខ្សែវ័ណ្ឌពណ៌មាស រាងដងធ្នូសំប៉ែតមួយផង។

រូបគំនូរម្ចូក និងសញ្ញាស័ក្តិម្ចូកសម្រាប់មន្ត្រីៈ

- ឋានន្តរស័ក្តិឧត្តមមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី **១**
- ឋានន្តរស័ក្តិវរៈមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី **២**
- ឋានន្តរស័ក្តិអនុមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី **៣** នៃព្រះរាជក្រឹត្យនេះ។

**២- <u>អំពីស័ក្តិស្មា</u>**

ស័ក្តិស្មាមានផ្ទៃកម្ចីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់កួរស្រូវពណ៌មាស និងក្បាច់សន្លឹកភ្ញីទេសពណ៌មាសដាក់ខ្វែងគ្នា ហើយនៅពីលើក្បាច់ទាំងពីរនេះ មានរូបសញ្ញាក្រសួងមហាផ្ទៃពណ៌មាស និងនៅពីខាងលើរូបសញ្ញាក្រសួងមហាផ្ទៃ មានឡេវរូបព្រះសង្ហារពណ៌មាសមួយ។ បន្ទាប់មកមានបន្ទះក្បាច់ធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញក្នុងឋាន។ ផ្ទៃខាងក្រៅនៃក្បាច់ធ្មេញក្របីនេះ មានខ្សែពួរវេញព័ទ្ធជុំវិញពណ៌មាសបី សម្រាប់សំគាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី ពីរសម្រាប់សំគាល់ឋានន្តរស័ក្តិវរៈមន្ត្រី និងមួយសម្រាប់សំគាល់ឋានន្តរស័ក្តិអនុមន្ត្រី។

ខ្នាតស័ក្តិស្មាត្រូវបានកំណត់ដូចខាងក្រោមៈ

- បាតក្រោម ប្រវែង ៦សង្ទីម៉ែត្រ
- ទទឹងមុខកាត់ផ្នែកខាងលើ ប្រវែង ៤,៤០ សង្ទីម៉ែត្រ មានរាងកោងជាមុំទោល
- បណ្តោយពីលើដល់បាតក្រោម ប្រវែង ១៣ សង្ទីម៉ែត្រ

**៣- <u>អំពីស័ក្តិចុងកអាវ</u>**

ស័ក្តិចុងកអាវមានផ្ទៃកម្ចីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់កួរស្រូវពណ៌មាស និងក្បាច់សន្លឹកភ្ញីទេសពណ៌មាសដាក់ខ្វែងគ្នា ហើយមានរូបសញ្ញាក្រសួងមហាផ្ទៃពណ៌មាសនៅពីខាងមុខ។ បន្ទាប់មកមានបន្ទះក្បាច់ធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញ និងមានខ្សែពួរវេញពណ៌មាស នៅផ្នែកខាងលើភ្ជាប់ជាមួយចំហៀងខាងមុខបីសម្រាប់សំគាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី ពីរសម្រាប់សំគាល់ឋានន្តរស័ក្តិវរៈមន្ត្រី និងមួយសម្រាប់សំគាល់ឋានន្តរស័ក្តិអនុមន្ត្រី។

ខ្នាតស័ក្តិចុងកអាវត្រូវបានកំណត់ដូចខាងក្រោមៈ

- មានរាងជាប្រលេឡូក្រាម
- បណ្តោយ ប្រវែង ១១ សង្ទីម៉ែត្រ
- ទទឹង ប្រវែង ៤ សង្ទីម៉ែត្រ

**៤- <u>អំពីស័ក្តិចុងដៃអាវទាំងសងខាង</u>**

ស័ក្តិចុងដៃអាវ មានផ្ទៃកម្ចីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាស និងមានក្បាច់កួរស្រូវពណ៌មាសមួយនៅខាងចុង ហើយក្បាច់កួរស្រូវមួយទៀតខ្វែងនឹងគល់ក្បាច់ភ្ញីទេស។ បន្ទាប់មកមានបន្ទះក្បាច់ធ្មេញក្របីពណ៌មាសនៅជាយផ្នែកខាងលើ និងផ្នែកសងខាង។ ផ្ទៃខាងក្រៅ នៃក្បាច់ធ្មេញក្របីនេះមានខ្សែពួរវេញពណ៌មាសនៅផ្នែកខាងលើ និងផ្នែកចំហៀងទាំងសងខាងបីសម្រាប់សំគាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី ពីរសំគាល់ឋានន្តរស័ក្តិវរៈមន្ត្រី និងមួយសំគាល់ឋានន្តរស័ក្តិអនុមន្ត្រី។ នៅបាតក្រោមបង្អស់នៃសញ្ញាស័ក្តិចុងដៃអាវមានខ្សែពួរវេញពណ៌មាសមួយ។

ខ្នាតនៃស័ក្តិចុងដៃអាវទាំងសងខាង ត្រូវបានកំណត់ដូចខាងក្រោមៈ

- មានរាងបួនជ្រុងទ្រវែង
- បណ្តោយ ប្រវែង ៣២ សង្ទីម៉ែត្រ
- ទទឹង ប្រវែង ១១ សង្ទីម៉ែត្រ

រូបគំនូរសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវទាំងសងខាងសម្រាប់មន្ត្រីៈ

- ឋានន្តរស័ក្តិឧត្តមមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី **៤**
- ឋានន្តរស័ក្តិវរៈមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី **៥**
- ឋានន្តរស័ក្តិអនុមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី **៦** នៃព្រះរាជក្រឹត្យនេះ។

ដោយឡែកស័ក្តិស្មា ស័ក្តិចុងកអាវ និងស័ក្តិចុងដៃអាវទាំងសងខាង សម្រាប់នារីមានទំហំតូចជាងបុរស ១សង្ទីម៉ែត្រកន្លះ។

**៥- អំពីស័ក្តិខ្ទាស់លើដើមទ្រូងខាងឆ្វេងសម្រាប់នារី**

ស័ក្តិខ្ទាស់លើដើមទ្រូងខាងឆ្វេងសម្រាប់នារី មានផ្ទៃកម្ចីពណ៌ខៀវចាស់ រាងសាជី ដែលបាតក្រោមមានរាងពងក្រពើ និងកំពូលរាងជ្រលម កំពស់ ៥,៥០ សង្ទីម៉ែត្រ ទទឹង ៤,៥០ សង្ទីម៉ែត្រ។ ផ្ទៃកខាងក្នុងមានរូបសញ្ញាក្រសួងមហាផ្ទៃពណ៌មាស ទ្រដោយក្បាច់ក្ងួរស្រួវពណ៌មាសនៅខាងឆ្វេង ដាក់ខ្វែងគ្នានឹងក្បាច់សន្លឹកភ្ញីទេសនៅខាងស្តាំ។ បន្ទាប់មកមានក្បាច់ធ្មេញក្របីពណ៌មាសមួយព័ទ្ធអមផង។ ផ្ទៃកខាងក្រៅមានខ្សែពួរវេញព័ទ្ធអមពណ៌មាសបីសម្រាប់សំគាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី ពីរសម្រាប់សំគាល់ឋានន្តរស័ក្តិវរៈមន្ត្រី និងមួយសម្រាប់សំគាល់ឋានន្តរស័ក្តិអនុមន្ត្រី។

រូបគំនូរស័ក្តិខ្ទាស់លើដើមទ្រូងខាងឆ្វេង សម្រាប់មន្ត្រីជានារីទាំងបីឋានន្តរស័ក្តិ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ មានដូចក្នុងឧបសម្ព័ន្ធទី **៧** នៃព្រះរាជក្រឹត្យនេះ។

**ខ- ក្របខ័ណ្ឌមន្ត្រីក្រមការ**

សញ្ញាស័ក្តិសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ មានសណ្ឋាន និងមានការកំណត់បែងចែកទៅតាមប្រភេទឋានន្តរស័ក្តិ ដូចសញ្ញាស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ដែរ ប៉ុន្តែខុសគ្នាត្រង់សញ្ញាស័ក្តិសម្រាប់ក្របខ័ណ្ឌមន្ត្រីក្រមការមានពណ៌ប្រាក់។

រូបគំនូរមួក និងសញ្ញាស័ក្តិមួក សម្រាប់មន្ត្រីៈ

- ឋានន្តរស័ក្តិនាយក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី **៨**
- ឋានន្តរស័ក្តិក្រមការដើមខ្សែ មានដូចក្នុងឧបសម្ព័ន្ធទី **៩**
- និងឋានន្តរស័ក្តិក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី **១០** នៃព្រះរាជក្រឹត្យនេះ។

រីឯរូបស័ក្តិស្មា ស័ក្តិចុងកអាវ និងស័ក្តិចុងដៃអាវទាំងសងខាង សម្រាប់មន្ត្រីៈ

- ឋានន្តរស័ក្តិនាយក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី **១១**
- ឋានន្តរស័ក្តិក្រមការដើមខ្សែ មានដូចក្នុងឧបសម្ព័ន្ធទី **១២**
- និងសម្រាប់ឋានន្តរស័ក្តិក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី **១៣** នៃព្រះរាជក្រឹត្យនេះ។

ចំពោះស័ក្តិខ្ទាស់លើដើមទ្រូងខាងឆ្វេង សម្រាប់មន្ត្រីជានារីទាំងបីឋានន្តរស័ក្តិ នៃក្របខ័ណ្ឌមន្ត្រីក្រមការមានដូចក្នុងឧបសម្ព័ន្ធទី **១៤** នៃព្រះរាជក្រឹត្យនេះ។

# ជំពូកទី ៣
# ប្រភេទឯកសណ្ឋាន និងការប្រើប្រាស់

**មាត្រា ៤.–**

ប្រភេទឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ត្រូវបានកំណត់ដូចខាងក្រោម៖

**ក- <u>ឯកសណ្ឋានផ្លូវការ</u>**

**១- <u>ចំពោះបុរស:</u>** អាវវ៉ារីពណ៌ស និងខោជើងវែងពណ៌ស។

- អាវវ៉ារីមានផ្នែកខ្នង កបើក ដៃវែង មានប៉ូលស្មាទាំងសងខាង មានហោប៉ៅបួនដេរប៉ះ “ហោប៉ៅលើពីរដេរបត់ផ្នត់កណ្តាល មានគម្របរាងស្លឹកពោធិ ហោប៉ៅខាងក្រោមពីរ មានគំរបរាងចតុកោណកែង”។ ហោប៉ៅនីមួយៗមានឡេវបញ្ចោតមួយ ដែលមានរូបព្រះរាជសង្ហារពណ៌មាស ឬពណ៌ប្រាក់ទៅតាមឋានន្តរស័ក្តិ។ អាវនេះមានឡេវ ០៥ គ្រាប់ពណ៌មាស ឬពណ៌ប្រាក់ទៅតាមឋានន្តរស័ក្តិ។ ចុងដៃអាវកាត់រាងបំពង់ មានឡេវបញ្ចោតចំនួនបី រូបព្រះរាជសង្ហារពណ៌មាស ឬពណ៌ប្រាក់ទៅតាមឋានន្តរស័ក្តិ។
- ខោជើងវែងផ្ទេរបង្កប់ ចង្កេះត មានហោប៉ៅបួន “ខាងក្រោយពីរដេរបង្កប់ មានគម្របរាងស្លឹកពោធិ និងនៅចំហៀងពីរដេរបង្កប់តាមផ្ទេរ”។
- មួកកាសស្កេត ស័ក្តិស្មា ស័ក្តិចុងកអាវ និងស័ក្តិចុងដៃអាវ ពណ៌មាស ឬពណ៌ប្រាក់ប្រើទៅតាមឋានន្តរស័ក្តិ។
- ស្បែកជើងឃ្លុប កខ្លី ពណ៌ខ្មៅមានចងខ្សែ និងស្រោមជើងពណ៌ខ្មៅសម្រាប់ប្រើគ្រប់ឋានន្តរស័ក្តិ។
- អាវសឺមីពណ៌ស កឌុប និងក្រវ៉ាត់កពណ៌ខៀវចាស់តាមគំនូររូបភាពដូចគ្នាសម្រាប់ប្រើប្រាស់គ្រប់ឋានន្តរស័ក្តិ។

**២- <u>ចំពោះស្ត្រី</u>**

- មានអាវវ៉ារីដូចបុរសដែរ តែអាវនេះមានសម្រុងចុះពីក្រោមចង្កេះប្រវែង ២០ សង្ទីម៉ែត្រ។
- សំពត់ហ្ស៊ីបបត់ពណ៌ស មានសម្រុងលើភ្នែកគោល នៃស្មងជើងប្រវែងពី១០ ទៅ ១៥ សង្ទីម៉ែត្រ អនុលោមទៅតាមមាឌ និងកំពស់។
- ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ ពណ៌ស ឬពណ៌ខ្មៅ។

រូបគំនូរឯកសណ្ឋានផ្លូវការសម្រាប់បុរស និងស្ត្រី មានគំរូដូចក្នុងឧបសម្ព័ន្ធទី **១៥** នៃព្រះក្រឹត្យនេះ។

**ខ- <u>ឯកសណ្ឋានប្រពៃណីជាតិ</u>**

**១- <u>ចំពោះបុរស</u>**

- អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសម្រាប់ដាក់ស័ក្តិ និងគ្មានផ្នែកខ្នង។ អាវនេះមានហោប៉ៅចំនួន០៤ គឺហោប៉ៅខាងលើពីរដេរប៉ះចំកណ្តាល ចាប់ផ្នត់មួយ មានគម្របរាងស្លឹកពោធិ ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគម្របរាងចតុកោណកែង ហើយនៅលើគម្របហោប៉ៅទាំងបួននោះ មានឡេវរូបព្រះរាជសង្ហារពណ៌មាស ឬពណ៌ប្រាក់ទៅតាមឋានន្តរស័ក្តិ។ នៅចុងដៃអាវទាំងសងខាងមានឡេវបញ្ចោតបី រូបព្រះរាជសង្ហារពណ៌មាសឬពណ៌ប្រាក់ទៅតាមឋានន្តរស័ក្តិ។ អាវកុដពណ៌សនេះមានឡេវរូបព្រះរាជសង្ហារ ចំនួន ០៧ ពណ៌មាស ឬពណ៌ប្រាក់ទៅតាមឋានន្តរស័ក្តិ។

- សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ។
- ស្បែកជើងឃ្លុប កខ្លី ពណ៌ខ្មៅ មានចងខ្សែ ស្រោមជើងពណ៌ខ្មៅដល់ជង្គង់។

**២- <u>ចំពោះស្ត្រី</u>**

- សំពត់ហូលសំឡុយ ពាក់ជាមួយអាវប៉ាក់ ដៃខ្លី (លើកែងដៃ) មានកមូល។
- សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ ពាក់ជាមួយអាវប៉ាក់ ដៃវែង មានកមូល។
- ពានាក្រមាតាមពណ៌សំពត់ ឬពានាក្រមាពណ៌ស៊ីន្ទូន [១] (តាមពិធីការកំណត់)។

នៅលើក្រមាពានាផ្នែកខាងឆ្វេងនៃដើមទ្រូង មានខ្ទាស់សញ្ញាសំគាល់ទៅតាមឋានន្តរស័ក្តិផង។

- ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ ពណ៌ស ឬពណ៌ខ្មៅ។
- កាបូបយួរដៃ ពណ៌ស ឬពណ៌ខ្មៅ (មិនឱ្យស្ពាយទេ)។

រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសម្រាប់បុរស និងស្ត្រី ដែលស្លៀកសំពត់ផាមួងចងក្បិន មានគំរូដូចក្នុងឧបសម្ព័ន្ធទី **១៦** និងរូបគំនូរឯកសណ្ឋានប្រពៃណីជាតិស្ត្រី ដែលស្លៀកសំពត់ហូល ឬផាមួងសំឡុយ មានគំរូដូចក្នុងឧបសម្ព័ន្ធទី **១៧** នៃព្រះរាជក្រឹត្យនេះ។

**មាត្រា ៥.–**

ការប្រើប្រាស់ឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងមន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការនៃក្រសួងមហាផ្ទៃ ត្រូវបានកំណត់ដូចខាងក្រោម៖

- ឯកសណ្ឋានផ្លូវការសម្រាប់ប្រើប្រាស់ក្នុងឱកាសទិវាបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ។
- ឯកសណ្ឋានប្រពៃណីជាតិសម្រាប់ប្រើប្រាស់ក្នុងទិវាបុណ្យប្រពៃណីជាតិ និងសាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម ឬទីកន្លែងផ្សេងៗ។

## ជំពូកទី ៥

## របបកំណត់ឯកសណ្ឋាន និងសញ្ញាស័ក្ត

**មាត្រា ៦.–**

ត្រូវបានផ្តល់ជូនដល់មន្ត្រីម្នាក់ៗ នូវឯកសណ្ឋានផ្លូវការ ឯកសណ្ឋានប្រពៃណីជាតិ មួក សញ្ញាស័ក្តិ និងសម្ភារៈផ្សេងៗទៀតដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ មួយសម្រាប់ សម្រាប់ប្រើរយៈពេលបីឆ្នាំម្តង។

## ជំពូកទី ៦

## អវសានប្បញ្ញត្ត

**មាត្រា ៧.–**

បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៨.–**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០១

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានយកសេចក្ដីជម្រាបជូន

សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

សូមចុះហស្ថលេខា

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

**ស ខេង** **យូ ហុកគ្រី**

លេខ: ៦៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

សហការរៀបចំដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងកម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ (GIZ)-ចម្លងខ្ចឹមសារទាំងស្រុងតាមច្បាប់ដើម